# ជំពូក 17 ការប៉ាន់ស្មានបរិស្ថាន

## 17.1 ការត្រួតពិនិត្យដំបូងលើបរិស្ថាន

### 17.1.1 លក្ខណៈទូទៅ

ដូចបានរៀបរាប់ក្នុងជំពូក 9 បែបបទផ្លូវការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) ដូចមានក្នុងអនុក្រឹត្យ គឺមិនត្រូវការសំរាប់គំរោងណាដែលមានទំហំ/ចំណុះតិចជាងស្តង់ដារដូចមានបង្ហាញក្នុងតារាងនៅក្នុងផ្នែក 9.2 ។ ទោះបីជាយ៉ាងណាក៏ដោយនេះជាការចង្អុលបង្ហាញនៃការប្រព្រឹត្ត ការត្រួតពិនិត្យដំបូងលើបរិស្ថាន (IEE) គឺដើម្បីបញ្ជាក់ និង ផ្តល់ចំណុចសំខាន់ៗនៃការប៉ះពាល់ ដែលត្រូវត្រួតពិនិត្យ និង ការពិនិត្យមើលផ្សេងៗទៀត ។

IEE មានបី (3) ផ្នែក គឺ i) ការពិពណ៌នា និង ជ្រើសរើសគំរោង ii) ការពិពណ៌នាពីការដ្ឋាន និង iii) ការវាយតំលៃដំបូង ។

ការពិពណ៌នា និង ការជ្រើសរើសគំរោង គឺមានគោលបំណងបញ្ជាក់ពីសកម្មភាពគំរោង និង សមាសភាគពាក់ព័ន្ធដែលត្រូវត្រួតពិនិត្យ ។ ការពិពណ៌នាពីការដ្ឋាន គឺសង្ខេបពីឋានៈរបស់សេដ្ឋកិច្ចសង្គមបច្ចុប្បន្ន លក្ខខ័ណ្ឌធម្មជាតិ តំបន់ក្រោមការជ្រើសរើសជាក់លាក់ និង ពត៌មានផ្សេងៗ ។

ការវាយតំលៃដំបូងត្រូវធ្វើឡើងដើម្បីត្រួតពិនិត្យពីទំហំ និង វិសាលភាពនៃការប៉ះពាល់ដោយសកម្មភាពគំរោងនីមួយៗ សមាសភាគពាក់ព័ន្ធនឹងអាកាសធាតុបរិស្ថាន ។

### 17.1.2 ការពិពណ៌នា និង ការជ្រើសរើសគំរោង

ការជ្រើសរើសសមាសភាគគំរោងធំៗ គួរត្រូវបានធ្វើតាមរយៈការបញ្ជាក់ពីខ្នាត ឬ ទំហំ និង លក្ខណៈរបស់សមាសភាគនីមួយៗ ដើម្បីកំណត់ពីសមាសភាគដែលនឹងត្រូវត្រួតពិនិត្យ ។ ប្រសិនបើខ្នាត ឬ ទំហំត្រូវបានចាត់ទុកថាតូចល្មម ដែលមិនប៉ះពាល់ដល់លក្ខខ័ណ្ឌបរិស្ថានដែលបានរកឃើញសមាសភាគគំរោងនឹងត្រូវបានជ្រើសរើសយក ។ ការជ្រើសរើសនឹងធ្វើឡើងដោយប្រើទំរង់ 15 ក្នុងតារាងភ្ជាប់ I ។ គំរូនៃលទ្ធផលជ្រើសរើសនឹងបង្ហាញក្នុងតារាង 17.1 ។

### 17.1.3 ការពិពណ៌នាពីការដ្ឋាន

#### (1) ស្ថានភាពសេដ្ឋកិច្ចសង្គមបច្ចុប្បន្នរបស់តំបន់គំរោង

សេចក្តីជាបន្តបន្ទាប់ដែលគួរតែពិពណ៌នាដោយសង្ខេប :

- ភាពជាម្ចាស់ដី និង ដីប្រើប្រាស់
- សកម្មភាពសេដ្ឋកិច្ច
- ទំនៀមទម្លាប់ (សិទ្ធិប្រើប្រាស់ទឹក)
- ប្រជាជនច្រើន ឬ សហគមន៍
- សុខភាព និង អនាម័យ
- ចំនួនប្រជាជន

(2) **លក្ខណៈធម្មជាតិនៃតំបន់គំរោង**

ដើម្បីការអភិវឌ្ឍន៍គំរោងកសិកម្ម ត្រូវពិពណ៌នាដោយសង្ខេបនូវមុខការមួយចំនួនគឺ :

- អាកាសធាតុ - ឋានលេខាសាស្ត្រ - ជលសាស្ត្រ និង ការដោះទឹក
- ដី - ព្រៃឈើ និង ដំណាំដុះឯង - ពូជកំរមាន ឬ បរិស្ថានវិទ្យាខ្សោយ
- គុណភាពទឹក

(3) **តំបន់ក្រោមការជ្រើសរើសជាក់លាក់**

អ្វីដែលមាននៅក្នុងតំបន់ជាបន្តបន្ទាប់ គួរតែបញ្ជាក់នៅក្នុង/ជុំវិញតំបន់គំរោង ។

- ពពួកសត្វ និង រុក្ខជាតិនៅក្នុង CITES
- ដីសើមដែលបានជ្រើសរើសនៅក្នុងសន្ធិសញ្ញារ៉ែមសារ (Ramsar)
- តំបន់បេតិកភណ្ឌនៅក្រោមសន្ធិសញ្ញាបេតិកភណ្ឌពិភពលោក
- តំបន់ការពារ ( ឧទ្យានជាតិ ជំរកសត្វព្រៃ ។ល ។) និង
- ផ្សេងៗ ( តំបន់ព្រៃសម្បទាន តំបន់គំរោងដាំព្រៃឈើឡើងវិញ ។ល ។)

(4) **ពត៌មានផ្សេង**

បញ្ហាសង្គមដទៃទៀត ដែលប៉ះពាល់ភ្លាមៗលើធម្មជាតិនៅក្នុងតំបន់គំរោង គួរតែវាយមុខម្តងមួយៗ និង ពិពណ៌នាដោយសង្ខេបនៅក្នុងនេះ ។ ការពិពណ៌នាពីការដ្ឋានគួរតែសង្ខេបនៅក្នុងទំរង់ 16 ក្នុងតារាងភ្ជាប់ 1 ។ គំរូរបស់ការពិពណ៌នាពីការដ្ឋាននឹងបង្ហាញក្នុងតារាង 17.2 ។

## 17.1.4 ការវាយតំលៃដំបូង

ការវាយតំលៃដំបូងត្រូវធ្វើដោយការចុះបញ្ជីជាសាធារណៈ (Matrix) រវាងសមាសភាពធំរបស់គំរោងដែលបានបញ្ជាក់នៅក្នុងដំណើរការជ្រើសរើស (ផ្នែក 17.1.2) និង កត្តាបរិស្ថានដែលអាចប៉ះពាល់ដោយសមាសភាគ ។ ទំហំនៃការប៉ះពាល់ដែលបានប្រមើលទុកត្រូវបានវាយតំលៃជាប្រាំចំណាត់ថ្នាក់ដូចខាងក្រោម :

A: ទំហំខ្ពស់ណាស់នៃការប៉ះពាល់ដែលប្រមើលទុក

B: ទំហំទាបណាស់នៃការប៉ះពាល់ដែលប្រមើលទុក

X: គ្មានអានុភាព នឹងកើតមានឡើង និង

*: គ្មានទំនាក់ទំនង

ការប៉ះពាល់ ឬ អានុភាពត្រូវបានចែកជាពីរប្រភេទ គឺ :

+: អានុភាពវិជ្ជមាន នឹង កើតមានឡើង និង

-; អានុភាពអវិជ្ជមានដែលប្រមើលទុក ។

ការវាយតំលៃដំបូងគួរសំរាប់ត្រួតពិនិត្យបញ្ហាសេដ្ឋកិច្ចសង្គម និង បញ្ហាបរិស្ថានធម្មជាតិ ។ បញ្ហា

ទាំងនេះដែលត្រូវត្រួតពិនិត្យនឹងបង្ហាញក្នុងទំរង់ 17 ក្នុងតារាងភ្ជាប់ 1 ។ គំរូនៃការវាយតំលៃដំបូងនឹងបង្ហាញក្នុងតារាង 17.3 ។

## 17.2 ការវាយតំលៃការប៉ះពាល់បរិស្ថាន

### 17.2.1 ការស្រាវជ្រាវលំអិត

ក្នុងករណីដែល i) លក្ខខ័ណ្ឌសំខាន់ៗបរិស្ថានដែលបានបញ្ជាក់ (ផ្នែក 9.3) ឬ ii) ទំហំខ្ពស់នៃការប៉ះពាល់បរិស្ថានដែលកើតមានឡើង (ផ្នែក 17.1) ។ នេះជាការណែនាំអនុវត្តការស្រាវជ្រាវលំអិត ។ ការស្រាវជ្រាវលំអិតដែលធ្វើ គឺសង្កត់ធ្ងន់លើលក្ខខ័ណ្ឌបរិស្ថាន/កត្តាដែលបានបញ្ជាក់ជាក់លាក់ ដែលត្រូវយកចិត្តទុកដាក់ជាបន្តបន្ទាប់ ។ វាជាការប្រសើរដែលលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញជាផែនទី គំនូរព្រាង និងតារាង ។វិធីសាស្ត្រនៃការស្រាវជ្រាវ និង ឧបករណ៍ដែលយកមកអនុវត្ត ក៏គួរតែបញ្ជាក់ផងដែរ ។

#### (1) និយមន័យនៃទំហំវិសាលភាពរបស់ការស្រាវជ្រាវ

តំបន់ភូមិសាស្ត្រ គឺសំដៅទៅលើឥទ្ធិពលប៉ះពាល់បរិស្ថានដោយគំរោង គួរតែត្រូវពន្យល់មុនពេលការចាប់ផ្តើមការស្រាវជ្រាវលំអិត ។ និយមន័យនៃតំបន់ដែលនឹងត្រូវស្រាវជ្រាវគឺ អាស្រ័យលើកត្តាសំរាប់ជាច្រើន ឧទាហរណ៍:

- ខ្នាត ឬ ទំហំរបស់គំរោង និង ប្រភេទនៃសកម្មភាពគំរោង
- តំបន់ទាំងឡាយដែលប៉ះពាល់ផ្ទាល់ដោយគំរោង និង តំបន់ដែលប៉ះពាល់ដោយប្រយោល
- ភាពប្រែប្រួលនៃតំបន់នៅជុំវិញពីធម្មជាតិ ឬ ទស្សនៈសេដ្ឋកិច្ចសង្គម និង
- ភាពផ្សេងៗគ្នានៃបរិស្ថាននៅក្នុង/ជុំវិញការដ្ឋានគំរោង ។ កត្តាទាំងអស់នេះហើយដែលត្រូវពិចារណាក្នុងការឱ្យអត្ថន័យនៃតំបន់ស្រាវជ្រាវ ។

#### (2) តម្រូវការពេលវេលាសំរាប់ការស្រាវជ្រាវ

ការងារស្រាវជ្រាវមួយចំនួនត្រូវការនូវពេលវេលាជាក់លាក់ក្នុងឆ្នាំ ។ ឧទាហរណ៍នៅកន្លែងដែលមានរដូវភ្លៀង និង រដូវប្រាំងផ្សេងៗគ្នា ការស្រាវជ្រាវសំរាប់ពីររដូវ ឬ បន្ថែមពីររដូវដែលផ្លាស់ប្តូរអាចនឹងត្រូវការ ។ ចំណែកឯពូជសត្វនានាដូចជា បក្សីដែលផ្លាស់ប្តូរទីកន្លែងរស់នៅដែលអាចនឹងមានទៅតាមរដូវមួយពិតប្រាកដ ។ ត្រូវយកចិត្តទុកដាក់ពីកត្តាពេលវេលាដែលត្រូវការទាំងអស់នេះ ។

### 17.2.2 ការព្យាករណ៍ពីការប៉ះពាល់ និង ការវាយតំលៃ

ពឹងផ្អែកលើលទ្ធផលនៃការស្រាវជ្រាវលំអិត វាជាប្រការសំខាន់ក្នុងការព្យាករណ៍ពីឥទ្ធិពលនៃការប៉ះពាល់នាពេលអនាគតទៅលើលក្ខខ័ណ្ឌបរិស្ថានជាក់លាក់/បរិមាណ ឬ គុណភាពសារធាតុដើម្បីអភិវឌ្ឍវិធានការណ៍បន្ថយការប៉ះពាល់ទាំងឡាយ ។ ការប៉ះពាល់នៅក្នុងការព្យាករណ៍នេះកត្តាជាបន្តបន្ទាប់ដែលត្រូវយកចិត្តទុកដាក់ ។

- ប្រពលភាព
- វិសាលភាព
- និរន្តរភាព
- ភាពញឹកញាប់
- ភាពមិនអាចប្រែប្រួលបាន
- ពេលគ្រោងទុក និង ការពន្យា
- ភាពប្រាកដប្រជា
- ការប៉ះពាល់ផ្ទាល់ ឬ ប្រយោល
- ភាពមិនច្បាស់លាស់
- បញ្ហផ្សេងៗដែលជាប់ទាក់ទង
- ការប៉ះពាល់ដែលអាចមើលឃើញ ឬ មើលមិនឃើញ

ការប៉ាន់ស្មានទាំងឡាយ គឺជាមូលដ្ឋានសំរាប់វាយតំលៃពីការប៉ះពាល់ ដែលបានព្យាករណ៍ដោយមធ្យោបាយនៃវិធីសាស្ត្រជាបន្តបន្ទាប់ ។

1) "ការវាយតំលៃជាក់លាក់" គឺជាមូលដ្ឋានលទ្ធផលនៃការប្រៀបធៀបការប៉ះពាល់ ដែលបានព្យាករណ៍ជាមួយស្តង់ដារបរិស្ថានកំណត់ ឬ ស្តង់ដារទាំងឡាយ (គឺស្តង់ដារគុណភាពទឹក ស្តង់ដារកាកសំណល់បង្ហូរចូលទន្លេ ។ល។)

2) "ការវាយតំលៃដែលជាប់ពាក់ព័ន្ធ" គឺអាស្រ័យលើលទ្ធផលនៃការប្រៀបធៀបការប៉ះពាល់ដែលបានព្យាករណ៍ទាយជាមួយកំរិតបរិស្ថានដែលមានស្រាប់ ។ លើសពីនេះទៀតជាការប្រសើរត្រូវពិគ្រោះជាមួយនឹងអ្នកចូលរួមដូចជា រដ្ឋអំណាចមូលដ្ឋាន សហគមន៍ និង NGOs អំពីការប៉ាន់ស្មាននូវការប៉ះពាល់ដែលបានព្យាករណ៍ទុក ។

## 17.3 កម្មវិធីអភិរក្សបរិស្ថាន

វាចាំបាច់ក្នុងការបង្កើតកម្មវិធីអភិរក្សបរិស្ថានក្នុងករណីដែល :

i) ការប៉ះពាល់ដែលបានព្យាករណ៍ទុក ត្រូវប៉ាន់ស្មានថាលើសពីស្តង់ដារ/ការកំណត់របស់ការវាយតំលៃជាក់លាក់

ii) ការប៉ះពាល់ដែលបានព្យាករណ៍ទុក ត្រូវប៉ាន់ស្មានថាបានបង្កភាពធ្ងន់ធ្ងរ និង ភាពយ៉ាប់យ៉ឺនដែលមិនអាចចៀសវាងបានលើបរិស្ថានដែលមានស្រាប់ទៅតាមការវាយតំលៃមិនជាក់លាក់ និង

iii) ធ្វើឱ្យការប៉ះពាល់តិចជាអប្បបរមា ត្រូវបានទទួលស្គាល់ និង គួរឱ្យចូលចិត្តទោះបីជាទំហំនៃការប៉ះពាល់មិនបានប្រមើលទុកនៅក្នុងដំណាក់កាល IEE ។

កម្មវិធីអភិរក្សបរិស្ថាន មានរួមបញ្ចូលទាំងវិធានការណ៍កាត់បន្ថយការប៉ះពាល់ និង ត្រួតពិនិត្យ ។ ឯកសារកិច្ចព្រមព្រៀងសំរាប់ការសាងសង់ ជាញឹកញាប់មានបញ្ចូលកម្មវិធីអភិរក្សបរិស្ថានមួយចំណែក ដើម្បីនឹងថ្លែងបញ្ជាក់ឱ្យច្បាស់លាស់ពីវិធីដែលអ្នកម៉ៅការសាងសង់ ត្រូវបញ្ចូលការយកចិត្តទុកដាក់ពីបរិស្ថាននៅក្នុងការងាររបស់ពួកគេ ។

ក្រៅពីនេះសហប្រតិបត្តិការណ៍ និង សហការណ៍ជាមួយស្ថាប័នផ្សេងៗ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (MAFF) ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ក្រសួងបរិស្ថាន (MOE) អង្គការមិនមែនរដ្ឋាភិបាលនានា (NGOs) រដ្ឋអំណាចមូលដ្ឋាន សហគមន៍ ។ល។ ដែលម្តងម្កាលមិនអាចចៀសវាងបាន ដើម្បីធានានូវប្រសិទ្ធិភាពនៃកម្មវិធីអភិរក្សបរិស្ថាន ។

(1) **វិធានការណ៍កាត់បន្ថយការប៉ះពាល់**

អាស្រ័យលើទំហំនៃការប៉ះពាល់ដែលបានបញ្ជាក់នៅក្នុងដំណើរការ IEE ឬ ការប៉ះពាល់ដែលបានព្យាករណ៍ទុក និង ការប៉ាន់ស្មាន វិធានការណ៍សំរាលទាំងឡាយត្រូវបានយកមកពិចារណាដើម្បីបន្ថយការប៉ះពាល់ផ្សេងៗ ។ វិធានការណ៍ គួរតែផ្សព្វផ្សាយផ្តល់សេចក្តីលំអិតលើមុខការងារដែលបានស្នើឡើង និង កំណត់ពេលវេលា ។ តារាងជាបន្តបន្ទាប់គឺជាយុទ្ធសាស្ត្រមូលដ្ឋានសំរាប់អភិវឌ្ឍវិធានការណ៍ (NEPA/USA) ។

**តារាង យុទ្ធសាស្ត្រមូលដ្ឋានសំរាប់អភិវឌ្ឍវិធានការណ៍កាត់បន្ថយការប៉ះពាល់**

| | |
|---|---|
| ការចៀសវាង | ចៀសវាងនូវការប៉ះពាល់ទាំងអស់ ដោយមិនបានចាត់វិធានការណ៍ ឬ ចាត់វិធានការណ៍ជាផ្នែកៗ |
| ការធ្វើឱ្យតិច ជាអប្បបរមា | ធ្វើឱ្យការប៉ះពាល់មានតិចជាអប្បបរិមា ដោយកំរិតកំណត់ ឬ ទំហំវិធានការណ៍ និងការអនុវត្តន៍របស់វិធានការណ៍ ។ |
| កែសម្រួល | កែសំរួលការប៉ះពាល់ដោយជួសជុលស្តារឡើងវិញ ឬ ធ្វើឱ្យដូចដើមវិញនូវប្រសិទ្ធិភាពនៅក្នុងបរិស្ថាន |
| ការបន្ថយ/ការបំបាត់ | បន្ថយ ឬ បំបាត់ការប៉ះពាល់ ដោយប្រតិបត្តិការការពារ និង ការថែទាំក្នុងកំឡុងពេលរបស់វិធានការណ៍ |
| ការសង | សំណងសំរាប់ការប៉ះពាល់ដោយផ្លាស់ប្តូរ ឬ ផ្តល់ធនធានជំនួស ឬ បរិស្ថាន |

វិធានការណ៍ទាំងឡាយដែលអាចធ្វើទៅបាន និង ថ្លៃប្រសិទ្ធិភាពដែលអាចបន្ថយការប៉ះពាល់បរិស្ថានត្រូវតែបានជ្រើសរើស និង អភិវឌ្ឍន៍ ។ វិធានការណ៍ទាំងនេះ គួរត្រូវបានផ្តល់អាទិភាពទៅតាមសារៈសំខាន់ដែលទាក់ទងដើមទុន និង ចំណាយដែលមានជារឿយៗ និង ស្ថាប័នរបស់ពួកគេ ព្រមទាំងតំរូវការនៃការបណ្តុះបណ្តាលគោលបំណងរបស់វិធានការណ៍ ឬ ឧទាហរណ៍មានបង្ហាញក្នុងតារាង 17.4 ។

(2) **ការត្រួតពិនិត្យ**

ផែនការត្រួតពិនិត្យ គួរតែត្រូវបានអភិវឌ្ឍន៍ ពិចារណាពីទស្សនៈពីរជាបន្តបន្ទាប់ :

1) "ត្រួតពិនិត្យការប្រព្រឹត្តតាម" គឺដើម្បីបញ្ជាក់ពីការអនុវត្តន៍វិធានការណ៍កាត់បន្ថយការប៉ះពាល់ ។
2) "ត្រួតពិនិត្យប្រសិទ្ធិភាព" គឺដើម្បីកំណត់ថាតើវិធានការណ៍សំរាលដែលបានស្នើ បំរើមុខងារដែលបានគ្រោងទុក និង ប្រសិទ្ធិភាពរបស់ពួកគេឬទេ ។ សកម្មភាពត្រួតពិនិត្យ វិធីសាស្ត្រ កាលវិភាគពេលវេលា ការទទួលខុសត្រូវ និង ការចំណាយ គួរតែបញ្ជាក់ពីវិសាលភាពដែលអាចធ្វើបាន ។

## 17.4 ការអនុវត្តន៍របស់កម្មវិធីអភិរក្សបរិស្ថាន

វិធានការណ៍កាត់បន្ថយការប៉ះពាល់ និង ត្រួតពិនិត្យគួរតែបំពេញទៅតាមកម្មវិធីអភិរក្សបរិស្ថាន

នៅក្រោយពេលដែលគំរោងបានចាប់ផ្តើម (គឺការគ្រោងការលំអិត ការងារសាងសង់ និង ដំណាក់កាលប្រតិបត្តិការ និង ការថែទាំ) ។

ក្នុងករណីដែល i) ប្រសិទ្ធិភាពដែលបានសញ្ជឹងទុករបស់វិធានការណ៍សំរាលទាំងឡាយមិនបានបង្ហាញឱ្យឃើញ ឬ ii) ការប៉ះពាល់បរិស្ថានដែលមិនបានប្រមើលទុកកើតឡើងមូលហេតុ គួរត្រូវបានបញ្ជាក់ និង វិធានការណ៍ទប់ទល់ដ៏ត្រឹមត្រូវគួរតែអភិវឌ្ឍ និង ប្រតិបត្តិបើមានការចាំបាច់ ។

# ជំពូក 18 ការវាយតំលៃគំរោង

## 18.1 ស្ថានភាពទូទៅ

ការវាយតំលៃគំរោងជាទង្វើមួយសំរាប់សេដ្ឋកិច្ច និង ការកំណត់ថវិកានៃគំរោង ដែលស្របជាមួយនឹងការបញ្ជាក់នូវបច្ចេកទេសត្រឹមត្រូវរបស់គំរោង ។ ក្នុងគំរោងមួយត្រូវតែផ្តោតទៅលើការអភិវឌ្ឍន៍ លើការស្រោចស្រព និង ការដោះទឹកបញ្ចេញ ដែលវាជាការវាយតំលៃនៅតាមគំរិតនៃសេដ្ឋកិច្ចដែលឈានទៅកំណត់នូវមធ្យោបាយសេដ្ឋកិច្ចដែលអាចមានរបស់គំរោង និង ដើម្បីប្រៀបធៀបជាមួយនឹងជម្រើសវិនិយោគផ្សេងៗដទៃទៀត ។ លើសពីនេះទៅទៀត គំរោងជាអ្នកកំរិតនូវការ ប្រែប្រួលនៃហិរញ្ញវត្ថុ និង និរន្តរភាពនៃសេដ្ឋកិច្ចតាមលំនៅដ្ឋាន ដែលជាប់ទាក់ទងនឹងការប្រៀបធៀប ការរៀបចំឡើងនាពេលបច្ចុប្បន្ន និង លក្ខខ័ណ្ឌទាំងឡាយនៅពេលអនាគតក្រោមរូបភាពដែលគ្មានការអនុវត្តន៍គំរោង ។ ដំណើរការប្រព្រឹត្តនៅការវាយតំលៃគំរោងសរុបដូចខាងក្រោម :

រូបភាព ការវាយតំលៃគំរោង



## 18.2 ការវិភាគស្ថានតំលៃ

### 18.2.1 តំលៃហិរញ្ញវត្ថុនៅលើកសិដ្ឋាន

តំលៃនៅលើកសិដ្ឋាន នៃផលិតផលកសិកម្មទាំងអស់ ជាទូទៅតែងតែផ្លាស់ប្តូរទៅតាមទីកន្លែងលក់នីមួយៗ ។ ការកំណត់ពិតប្រាកដនៃ Farm gate prices នៃផលិតផលកសិកម្មបង្ហាញដូចតទៅ :

1. សេក្តីបញ្ជាក់នៃបទពិសោធន៍ជោគជ័យនៃការធ្វើជំនួញរបស់កសិករនៅក្នុងតំបន់ និង បរិមាណរបស់ពួកគេ
   1) ទីកន្លែង : បទពិសោធន៍នៃការចែកចាយលក់ដូររបស់កសិករនៅតាមបណ្តោយផ្លូវ គេហដ្ឋានតាមទីផ្សារ ។ល។
   2) ពេលវេលា : នារដូវប្រមូលផលកាត់ តាមបណ្តាខែនីមួយៗ ។ល។
2. សេចក្តីបញ្ជាក់នូវតំលៃជោគជ័យរបស់ជំនួញតាមរដូវ និង ទីកន្លែង
3. ការគិតនូវតំលៃនៅលើកសិដ្ឋាន យោងទៅលើបរិមាណនៃការលក់ដូរតាមរដូវ និង ទីកន្លែង (បរិមាណមធ្យម)

តំលៃនៃសំភារៈកសិកម្ម ដូចជាជី ពូជ និង ឧបករណ៍ដទៃទៀត នឹងត្រូវប្រមូលទិញនៅតាមហាងលក់នៅក្នុងតំបន់ ហើយក្នុងខណៈដែលកសិករស្វះស្វែងរកចំណូលសរុប និង ចំណាយនៃការធ្វើដំណើរដោយខ្លួនគេផ្ទាល់ ។ តំលៃនៅលើកសិដ្ឋានសរុប គឺជាការកំណត់នូវតំលៃលក់ទាំងអស់តាមទីផ្សារ និង តំលៃនៃការធ្វើដំណើររវាងគេហដ្ឋានរបស់កសិករ និង ផ្សារ ។ សំណួរនៃការសិក្សាវាស់ស្ទង់តំរូវទៅតាមការអនុវត្តន៍ដើម្បី ប្រមូលបាននូវពត៌មានតំលៃប្រាកដ បទពិសោធន៍ក្នុងការលក់ដូររបស់កសិករ ធនធានសរុប ប្រភេទនៃមធ្យោបាយធ្វើដំណើរ បរិមាណនៃការលក់ដូរ និង ការប្រព្រឹត្តទៅនៃតំលៃ ។ ទិន្នន័យនៃការប្រមូល វាជាការវិភាគសំរាប់ការកំណត់ពិតប្រាកដនូវតំលៃតំណាងឱ្យតំលៃនៅលើកសិដ្ឋាន នៃកសិផល និង តំលៃសរុប ។

### 18.2.2 តំលៃសេដ្ឋកិច្ចនៅលើកសិដ្ឋាន

#### (1) តំរូវការពត៌មានសំរាប់ការប៉ាន់ស្មានតំលៃក្នុងលក្ខណៈសេដ្ឋកិច្ច

តំរូវការពត៌មានជាបន្តបន្ទាប់នេះ គឺសំរាប់ការកំណត់នូវតំលៃដែលមានលក្ខណៈសេដ្ឋកិច្ច នៃការធ្វើចរាចរទំនិញ :

1. តំលៃនៃការធ្វើចរាចរក្នុងមួយឯកត្តា នៅក្នុងប្រទេសមួយ (ភាគច្រើនបំផុតនៃទីផ្សារ ជំនួញទៅលើផែអន្តរជាតិ ព្រមទាំងការបង់នៅលើផ្លូវធ្វើដំណើរ និង តំបន់គំរោង) និង ចំណុចតំបន់នៃទីកន្លែងចរាចរទំនិញអន្តរជាតិ និង តំបន់ទីផ្សារពិភពលោក ។
2. ការប្រព្រឹត្តទៅនៃតំលៃក្នុងមួយឯកត្តានៃផលិតផលទាំងពួង ដូចជា អង្ករដែលចេញមកពីស្រូវ និង ស្ករបានមកពីអំពៅ
3. តំលៃនៃផលិតផលទាំងអស់ ដូចជា កន្ទក់ ចុងអង្ករ ចំបើង អង្កាម ។ល។
4. នាំចូល និង នាំចេញបរិមាណទំនិញចរាចរ ដែលជាប់ទាក់ទងទៅនឹងគំរោង ដើម្បីនឹងកំណត់តំលៃពិតប្រាកដនៃតុល្យភាពទំនិញ ។

5. សរុបនូវកំរិតនៃការនាំចូល និង នាំចេញ

6. អត្រាភាស៊ី កំរិតនៃពន្ធបន្ថែមសំរាប់ចរាចរទំនិញ និង សកម្មភាពជំនួញទាំងឡាយ

7. ភាពបំរុងទុកសំរាប់ការនាំចូល និង នាំចេញ

8. កំលាំងពលកម្មដែលអាចមានប្រចាំឆ្នាំសំរាប់ការដាំដុះ និង កំលាំងពលកម្មដែលមិនមែនជាតំរូវការជាមួយលក្ខខ័ណ្ឌរបស់គំរោង

9. ការចែកតំលៃនៃគំរោងរយៈពេលយូរ យោងទៅលើតំលៃផលិតផលព្យាករណ៍នៅលើធនាគារពិភពលោក ( World Bank Commodity Price ) និង

10. កត្តានៃការផ្លាស់ប្តូរស្តង់ដារ យោងទៅលើទិន្នន័យនៃ Item 5 6 និង 7 ( Ref. Table 18.1 )

**(2) ការប៉ាន់ស្មាននៃតំលៃសេដ្ឋកិច្ច**

តំលៃសេដ្ឋកិច្ចនៅលើកសិដ្ឋាន នៃការសរុបចរាចរទំនិញកសិដ្ឋាន និង លទ្ធផលសរុបដែលជាការប៉ាន់ស្មានដោយប្រើប្រាស់នូវពត៌មាននៃការព្យាករណ៍តំលៃផលិតផលនៅលើធនាគារពិភពលោក ។ តំលៃគំរោងក្នុងរយៈពេលវែងគឺជាការសំរេចយកពិតប្រាកដក្នុងមួយឆ្នាំនៃសារៈផលប្រយោជន៍គំរោង យោងលើការអនុវត្តន៍កម្មវិធីនៃគំរោង នៅក្នុងការពិចារណា ដែលយ៉ាងហោចបំផុតគឺបន្ទាប់ពីបញ្ចប់នូវការងារសាងសង់ ។ ក៏ប៉ុន្តែវាប្រើរយៈពេលវែង ដូចជាច្រើនជាង 10 ឆ្នាំ យោងទៅលើភាពពុំទុកចិត្តនៃការព្យាករណ៍ ។ តំលៃនៃសេដ្ឋកិច្ចសំរាប់ចរាចរទំនិញ គឺជាការប៉ាន់ស្មានតំលៃ អាស្រ័យលើរូបមន្តបន្ទាប់ ( Ref. Table 8.2 ) :

**តារាង រូបមន្តនៃការប៉ាន់ស្មានតំលៃសេដ្ឋកិច្ចសំរាប់ទំនិញពាណិជ្ជកម្ម**

| រាយសេចក្តី | គុណភាព តំលៃនាំចេញ | | គុណភាព តំលៃនាំចូល | |
|---|---|---|---|---|
| 1. តំលៃព្រំដែន | | | | |
| ផែនការតំលៃពិភពលោក | | | | |
| តំលៃមិនប្រែប្រួលនៅឆ្នាំ 1990 | = | 100.0 | = | 100.0 |
| កត្តានៃតំលៃឯកត្តាការផលិត | x 1.01 | | x 1.01 | |
| តំលៃមិនប្រែប្រួលក្នុងឆ្នាំគំរោង | | 101.0 | | 101.0 |
| 2. ការកែសំរួលគុណភាព | x 0.9 | 90.9 | x 0.9 | 90.9 |
| 3. ដឹកជញ្ជូនតាមកប៉ាល់អន្តរជាតិ និង ការលើកដាក់ បើមាន | + | 20.0 | - | 20.0 |
| **4. តំលៃ CIF/FOB នៅកំពង់ផែ** | = | 110.9 | = | 70.9 |
| 5. តំលៃផែ ការលើកដាក់ និង ឃ្លាំង | + | 5.0 | - | 5.0 |
| **6. តំលៃនៅកំពង់ផែ** | = | 115.9 | = | 65.9 |
| 7. តំលៃដឹកជញ្ជូនរវាងកំពង់ផែ និង ទីក្រុងធំ | + | 5.0 | - | 5.0 |
| **8. តំលៃលក់ដុំក្នុងទីក្រុងធំ** | = | 120.9 | = | 60.9 |
| 9. តំលៃដឹកជញ្ជូនរវាងតំបន់គំរោង និង ទីក្រុងធំឬផែ | - | 10.0 | - | 10.0 |
| **10. តំលៃក្នុងតំបន់គំរោង** | = | 110.9 | = | 50.9 |
| 11. តំលៃកែច្នៃ | - | 3.0 | - | 3.0 |
| 12. តំលៃដឹកជញ្ជូនពីកសិដ្ឋាន | - | 2.0 | - | 2.0 |
| **13. តំលៃនៅលើកសិដ្ឋាន** | = | 105.9 | = | 45.9 |
| ចំណែករបស់ការនាំចេញ និង បរិមាណការនាំចេញ | 50% | | 50% | |
| 14. តំលៃលក្ខណៈសេដ្ឋកិច្ចជាមធ្យមនៅកសិដ្ឋានដែលលាំអៀង | | 75.9 | | |

តំលៃនៃការធ្វើចរាចរ សំរាប់តុល្យភាពតំលៃនៃការនាំចូល និង នាំចេញ គឺជាការគណនាអាស្រ័យលើកំរិតនៃចរាចរផលិតផលដូចខាងក្រោម:

**រូបភាព ជាន់ស្ពានតំលៃការនាំចេញ និង នាំចូល**




ទីផ្សារពលកម្មនៅជនបទ គឺជារឿយៗមានចំនួនលើស ក្រោមរូបភាពដែលមានឱកាសតិចតួចក្នុងការបំរើការងារ និង ភាពមមាញឹកក្នុងការងារស្រែចំការក្រោមលក្ខខ័ណ្ឌនៃការបំរើការងារ ។ ជោគជ័យនៃកំរិតហិរញ្ញវត្ថុនៅក្នុងកំលាំងពលកម្មកសិករដែលគ្មានជំនាញ ដែលត្រូវប្រែប្រួលទៅតាមពេលវេលានៃកំលាំងពលកម្ម (អត្រាថ្លៃឈ្នួលក្នុងកំរិតសេដ្ឋកិច្ច) ដែលប្រកាន់យកពិតប្រាកដ និង ភាពដែលមាននូវកំលាំងពលកម្ម កសិករស្ថិតក្នុងលក្ខណៈនៃការពិចារណា ។ កត្តាតំលៃដែលប្រមាណមើល (អត្រានៃប្រមាណថ្លៃឈ្នួលក្នុងតំលៃហិរញ្ញវត្ថុនៃកំលាំងពលកម្មកសិករ) ដែលអាចប្រែប្រួលតាមការអភិវឌ្ឍន៍ដោយប្រព័ន្ធស្រោចស្រព និង ប្រព័ន្ធបង្ហូរ តាមរយៈនៃការបង្កើនតំរូវការកំលាំងពលកម្ម ហើយនិងបង្កើននូវក្នុងស្រទាប់មហាជនផងដែរ ។ ការសិក្សានូវតុល្យភាពគឺជាទង្វើទៅលើប្រភពនៃអត្រានុកូសាស្រទិន្នន័យ តំរូវការកំលាំងពលកម្ម និង តំបន់ដាំដុះដោយគ្មាន និង មានលក្ខខ័ណ្ឌនៃគំរោង ។ អត្រាប្រមាណថ្លៃឈ្នួល គឺជាការសំរេចដ៏ប្រាកដមួយតាមការគណនានូវកត្តាប្រមាណមួយ និង កត្តាប្រែប្រួលនៃស្តង់ដារ ( Ref. Table 8.3 ) ។

## 18.3 ការវាយតំលៃនៃសេដ្ឋកិច្ច

### 18.3.1 ហិរញ្ញ-ថវិកាដាំដុះ និង ការបង្កើននូវកំរិតនៃផលិតផលសុទ្ធសារ (NPV)

អាស្រ័យលើប្រភពនៃហិរញ្ញ-ថវិកាដាំដុះ ថវិកាសេដ្ឋកិច្ចនៃការដាំដុះ វាគឺជាការរៀបចំដោយមាន និង គ្មានលក្ខខ័ណ្ឌគំរោង តាមតំរូវការនៃសំណើសំរាប់ចំណូលពីកសិដ្ឋាន និង សរុបកំលាំងពលកម្ម ឯកត្តាទិន្នផលដាំដុះ និង តំលៃសេដ្ឋកិច្ចរបស់ពួកគេ ។ ទិន្នផលព្យាករណ៍គឺជាការកំរិតនៃកំណើនក្រោមលក្ខខ័ណ្ឌនៃគំរោង រឺជាការបញ្ចូលទៅលើកំរិតដូចគ្នាតាមប្រភពនៃការត្រួតពិនិត្យជាទូទៅពីពេលកន្លងនៃទិន្នផល និង លក្ខខ័ណ្ឌ

នៅក្នុងតំបន់ ( Ref. Table 18.4 ) ។

ការស្រោចស្រពដោយប្រព័ន្ធផ្ទាល់ និង សារៈប្រយោជន៍នៃការបង្ហូរចេញ និង ត្រូវស្វែងរកនៅក្នុងកំណើននៃកំណើនផ្ទៃដាំដុះ និង សកម្មភាពគោលដៅដាំដុះរបស់គំរោង ។ ផលប្រយោជន៍សេដ្ឋកិច្ចគឺជាកំណើនមួយនៃកិរិតផលិតផលសុទ្ធសាធ (NPV) រវាងអនាគត ក្រោមគ្មាន និង មានលក្ខខ័ណ្ឌនៃគំរោង ។ កំណើននៃផលកំរៃនឹងកើនឡើងក្នុងមួយឆ្នាំបន្តិចម្តងៗ និង ឈានទៅដល់ទទួលបានផលប្រយោជន៍ដ៏ពេញលេញ បន្ទាប់ពីបីបួនឆ្នាំក្រោយមក ចាប់តាំងពីការបង្កើតឡើងនូវការផ្តល់ទឹកស្រោចស្រព និង ការគាំទ្រទៅដល់សកម្មភាពផ្សេងៗផងទាំងពួង ដូចជាការសន្មតជារឿយៗសំរាប់រយៈពេលបីទៅប្រាំឆ្នាំ យោងទៅលើបរិមាណផលប្រយោជន៍ និង ការគាំទ្រពីគំរោង ។ កំណើននៃផលប្រយោជន៍ ( កំរៃ) ពណ៌នាខាងក្រោម:

**រូបភាព ផលិតកម្មសុទ្ធដោយមាន ឬ គ្មានលក្ខខ័ណ្ឌគំរោង**




សេដ្ឋកិច្ចនៃការស្រោចស្រព និង ផលប្រយោជន៍នៃការបង្ហូរចេញ (Drainage) ក្នុងជំហាននៃការអភិវឌ្ឍន៍ដ៏ពេញលេញ ( កំណើននៃ NPV ) ត្រូវបានសរុបដូចខាងក្រោម:

**តារាង ផលប្រយោជន៍សេដ្ឋកិច្ចរបស់ការស្រោចស្រព និង ការបង្ហូរចេញ**

| គំរោង | ផ្ទៃ គំរោង (ហេកតា) | ល្បឿននៃការដាំដុះ (%) | | តំលៃផលិតកម្មសុទ្ធ ( លានរៀល) | | |
|---|---|---|---|---|---|---|
| | | គ្មាន គំរោង | មាន គំរោង | គ្មាន គំរោង | មាន គំរោង | កំណើន |
| | 3,50 | 92 | 137 | 2,106. | 8,149. | 6,043. |
| ចុះបញ្ជីជំរើស និង/ឬ ទាក់ទង និង ឈ្មោះគំរោង | | បង្ហាញពីការផ្លាស់ប្តូរដោយគំរោង | | ចំនួនរបស់ NPVs ដែលមានដំណាំផ្សេងៗអាស្រ័យផ្ទៃដីរបស់គេ | | NPV ( មាន-គ្មាន ) |

## 18.3.2 ភាពជារមធ្យមាននៃផលប្រយោជន៍

ផ្ទៃដីកសិកម្មដែលមានស្រាប់នឹងត្រូវរកបានមក និង ប្រើប្រាស់សំរាប់ការសាងសង់នូវប្រព័ន្ធស្រោចស្រព និង សំណង់បណ្តោះទឹកទាំងឡាយ ។ កិរិតនៃផលិតផលដែលរកបានក្នុងតំបន់នឹងត្រូវបាត់បង់ដោយ

ការអនុវត្តន៍គំរោង ។ ផលិតផលកសិកម្មដែលបានដឹងជាមុន ដូចជាកំរិតនៃផលិតផលសុទ្ធប្រចាំឆ្នាំដោយគ្មានគំរោង វាជាការគណនាសំរាប់ភាពអវិជ្ជមាននៃផលប្រយោជន៍នៅក្នុងការវាយតំលៃនៃសេដ្ឋកិច្ច ។

### 18.3.3 ការប៉ាន់ស្មានតំលៃសេដ្ឋកិច្ច

តំលៃនៃសេដ្ឋកិច្ចសំរាប់គំរោងស្រោចស្រព និង គំរោងបង្ហូរចេញ ដែលមានៈ (i) តំលៃសំរាប់វិនិយោគគំរោង (ii) តំលៃឧបករណ៍សំរាប់ប្រតិបត្តិការ និង ការជួសជុល (iii) តំលៃសំរាប់គ្រឿងបន្លាស់ និង ថ្លៃឈ្នួល ។ តំលៃសេដ្ឋកិច្ច ជាការប៉ាន់ស្មានដោយកត្តាបំលាស់ប្តូរទាំងអស់ ដែលទាក់ទងទៅនឹងសំណើ ទៅនឹងសមាសធាតុចូលរួមនៃហិរញ្ញវត្ថុអន្តរជាតិ និង តំលៃប្រាក់នៅក្នុងតំបន់ ដោយយោងទៅលើតំលៃឧបករណ៍ សំភារៈ និង កំលាំងពលកម្ម ។

តំលៃនៃសេដ្ឋកិច្ចសំរាប់វិនិយោគគំរោង គឺជាការចាត់ចំណាត់ថ្នាក់ដោយ : (i) តំលៃសំណង់សុទ្ធសាធ (ii) តំលៃនៃប្រតិបត្តិការ និង ការជួសជុល (iii) តំលៃអភិវឌ្ឍន៍ស្ថាប័ន (iv) តំលៃលើផ្នែករដ្ឋបាល (v) តំលៃវិស្វកម្ម និង (vi) តំលៃសំរាប់បំរុង (Physical Contingency) ។ តំលៃបំរុងជាតំលៃមិនបូកបញ្ចូលទៅក្នុងការវាយតំលៃនៃសេដ្ឋកិច្ច ។ តំលៃនៃសមធាតុចូលរួម គឺជាបំរុងទុកដោយឡែក១ពីគ្នា អាស្រ័យលើការអនុវត្តន៍នៃកម្មវិធីរបស់គំរោង ( Ref. Table 8.5 ) ។

ហិរញ្ញវត្ថុសំរាប់ប្រតិបត្តិការ និង ការជួសជុលថែទាំ និង តំលៃនៃគ្រឿងបន្លាស់ប្តូរ គឺប្រែប្រួលទៅតាមកំរិតសេដ្ឋកិច្ច ដោយសំណើនៃកត្តាប្រែប្រួលទាំងឡាយ ដែលទាក់ទងដូចគ្នាទៅនឹងតំលៃវិនិយោគរបស់គំរោង ។

តំលៃទាំងនោះ គឺជាការបំរុងទុកដោយឡែក១ពីគ្នា ទៅនឹងប្រភពដែលមានប្រចាំឆ្នាំ នៅលើការរីកចំរើននៃការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព និង ការប្រើប្រាស់ជីវិតពេលពេញនៃសំណង់ទាំងឡាយរបស់គំរោង ដូចជាទ្វារទឹក និង សំភារៈបរិក្ខារសំរាប់ប្រតិបត្តិការ និង ការជួសជុល ( Ref. Table 8.6 និង 8.7 ) ។

### 18.3.4 ការវាយតំលៃទៅលើសេដ្ឋកិច្ច

តំលៃនៃសេដ្ឋកិច្ច និង ផលប្រយោជន៍ដែលមានដំប្រសើរឡើង : (i) តំលៃវិនិយោគគំរោង ប្រតិបត្តិការ ការជួសជុល និង គ្រឿងបំលាស់ប្តូរ និង (ii) ប្រព័ន្ធស្រោចស្រព និង បង្ហូរ ព្រមទាំងភាពអវិជ្ជមាននៃផលប្រយោជន៍ វាគឺជាការរៀបចំសំរាប់ដំណើរសេដ្ឋកិច្ចនៃគំរោងដែលមានទាំងអស់ ។ ការត្រឡប់មកវិញនៃអត្រាសេដ្ឋកិច្ចខាងក្នុង (Economic Internal Rate of Returning EIRR) គឺជាអត្រាចុះតំលៃដែលកំរិតនៃពេលបច្ចុប្បន្ន ( តុល្យភាពនាពេលបច្ចុប្បន្នរវាងផលប្រយោជន៍នៃសេដ្ឋកិច្ច និង តំលៃ ) គឺសូន្យ ។ សារៈប្រយោជន៍នេះ និង អត្រាតំលៃ និង តំលៃបច្ចុប្បន្នក្នុងអត្រាបញ្ចុះតំលៃជាក់លាក់ វាក៏ជាការគណនាមួយសំរាប់ការកំរិតនៃប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់គំរោងទាំងអស់ ( Ref. Table 8.8 ) ។

**តារាង ប្រសិទ្ធិភាពនៃសេដ្ឋកិច្ចរបស់គំរោង**

| ការបរិយាយ | គំរោង A | គំរោង B | | | គំរោង C | | |
|---|---|---|---|---|---|---|---|
| | | B-1 | B-2 | B-3 | C-1 | C-2 | C-3 |
| EIR (%) | 10.8 | 10.2 | 10.7 | 7.2 | 9.9 | 13.1 | 7.6 |
| NPV (លានរៀល) (6.5% អត្រាបញ្ចុះតំលៃ) | | | | | | | |
| ចំណេញ | 64,04 | 450 | 450 | 214 | 105 | 110 | 101 |
| ចំណាយ | 40,78 | 302 | 291 | 197 | 72 | 60 | 89 |
| B - C | 23,26 | 148 | 159 | 17 | 33 | 50 | 12 |
| B / C | 1.6 | 1.5 | 1.5 | 1.1 | 1.5 | 1.8 | 1.1 |

## 18.4 ការវាយតំលៃហិរញ្ញវត្ថុ

### 18.4.1 ការវិភាគថវិកាសំរាប់កសិដ្ឋាន

ថវិកាកសិដ្ឋាន គឺជាការវិភាគដោយការសន្មតការប្រែប្រួលនៃការព្យាករណ៍នៅក្នុងប្រាក់ចំណូល និង ការចំណាយផ្សេងៗសំរាប់តំណាងឱ្យផ្ទះកសិដ្ឋាននីមួយៗ ។ ទំហំមធ្យមមួយនៃការអនុវត្តន៍កសិដ្ឋាន យោងលើ ការស្រាវជ្រាវវាស់ស្ទង់នៅលើកសិដ្ឋាន ឬក៏ស្ថិតិនៅលើដីដែលបានកាន់កាប់ អាចនឹងស្នើសំរាប់ការវិភាគថវិកា កសិដ្ឋាន ។ ក្នុងករណីដែលស្ថានភាពខុសពីមុននៃដីកាន់កាប់ វាជាការត្រួតពិនិត្យនៅក្នុងតំបន់គំរោង ដែល ចំណាត់ថ្នាក់បីនៃថវិកាកសិដ្ឋាន ដូចជាអនុវត្តន៍លក្ខណៈទ្រង់ទ្រាយតូច មធ្យម និង ធំ និង កំរិតនៃតំរូវការ ។ កសិដ្ឋានផ្សេងៗទៀត និង ប្រភពចំណូលដែលមិនមែនបានមកពីកសិដ្ឋាន ជាមួយនឹងការចំណាយផ្សេងៗសំរាប់ ជីវភាពរស់នៅ វាជាការសន្មតដូចគ្នាសំរាប់ទាំងពីរ គឺគ្មាន និង មានលក្ខខ័ណ្ឌគំរោង ដើម្បីធ្វើឱ្យប្រសើរឡើងនូវ ភាពប៉ះពាល់ទៅលើសេដ្ឋកិច្ចកសិដ្ឋានរបស់គំរោងទាំងឡាយ ( Ref. Table 8.9 ) ។

**តារាង ការចំរើនស្ថានថវិកាកសិដ្ឋាន (កសិករទ្រង់ទ្រាយមធ្យម)**

(ឯកតា : រៀល 000)

| ការបរិយាយ | គំរោង A & B | គំរោង C |
|---|---|---|
| គ្មានគំរោង | | |
| ចំណូល | 789. | 789. |
| ចំណាយ | 784. | 784. |
| ត្រៀមបំរុង | 4.6 | 4.6 |
| មានគំរោង | | |
| ចំណូល | 2,011. | 923. |
| ចំណាយ | 1,081. | 804. |
| ត្រៀមបំរុង | 930. | 118. |
| កំណើន (%) | | |
| ចំណូល | 155 | 17 |
| ចំណាយ | 38 | 3 |
| ត្រៀមបំរុង | 20,11 | 2,48 |

### 18.4.2 បរិមាណនៃការចំណាយសំរាប់តំលៃប្រតិបត្តិការ និង ការជួសជុលថែរក្សា

កំណើនប្រាក់ចំណូលកសិដ្ឋាន នឹងត្រូវបានចំណាយសំរាប់ការចំណាយបន្ថែមផ្សេងៗទៅលើជីវភាពរស់ នៅ ការសន្សំ និង តំលៃនៃប្រតិបត្តិការ និង ការជួសជុលថែទាំ សំរាប់ប្រព័ន្ធស្រោចស្រព និង សំណង់ដោះទឹក ទាំងអស់ ។ តំរូវការប្រចាំឆ្នាំសំរាប់តំលៃនៃប្រតិបត្តិការ និង ការជួសជុលថែទាំនៃគំរោងត្រូវបានប៉ាន់ស្មាន និង

ប្រៀបធៀបជាមួយនឹងកំណើនប្រាក់ចំណូលកសិដ្ឋានសុទ្ធសាធ ។ ក្នុងករណីដែលតារាងជាបន្តបន្ទាប់ដែលតំរូវការនៃតំលៃប្រតិបត្តិការ និង ការជួសជុលថែទាំ ស្ថិតនៅក្រោម 10% នៃកំណើនប្រាក់ចំណូលសុទ្ធសំរាប់គំរោង A និង B និង ក្រោម 20% សំរាប់គំរោង B ។

**តារាង តំលៃប្រតិបត្តិការ និង ការជួសជុលថែទាំ ដែលត្រូវការ និង ភាគរយនៃប្រាក់បំរុង**

| គំរោង | ថ្លៃ O & M (ហិរញ្ញវត្ថុ) | | |
|---|---|---|---|
| | ក្នុង 1 ហ.ត (រៀល 000) | ក្នុង 0.8 ហ.ត (រៀល 000) | ហិនដើម្បីបន្ថែមប្រាក់បំរុង (%) |
| គំរោង A | 76.7 | 61.4 | 7 |
| គំរោង B | | | |
| B-1 | 96.0 | 76.8 | 8 |
| B-2 | 96.0 | 76.8 | 8 |
| B-3 | 96.0 | 76.8 | 8 |
| គំរោង D | | (0.07 ហ.ត)* | |
| D-1 | 152.0 | 10.6 | 9 |
| D-2 | 268.0 | 18.8 | 16 |
| D-3 | 258.0 | 18.1 | 16 |

សំគាល់ : * ផ្ទៃដីស្រោចស្រពសំរាប់កសិករមធ្យម (0.8 ហ.ត)

### 18.4.3 ការគិតនូវហិរញ្ញវត្ថុនៃការបង្កើតឡើងនូវប្រតិបត្តិការ និង ការថែទាំ

និរន្តរភាពហិរញ្ញវត្ថុនៃសកម្មភាពប្រតិបត្តិការ និង ការជួសជុលថែទាំទាំងអស់ ដែលអនុវត្តដោយសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) និង ការិយាល័យប្រតិបត្តិការ និង ការជួសជុលថែទាំរបស់គំរោង គឺកំណត់ទៅលើប្រភពនៃប្រាក់ចំណូល និង តំរូវការចំណាយផ្សេងៗ ។ ប្រាក់ចំណូលដែលបានមកពីការស្វះស្វែងរកពីថ្លៃប្រើប្រាស់ទឹក (i) ការចាត់ចែងលើប្រតិបត្តិការ និង ការជួសជុល និង (ii) ការសន្សំសំរាប់ការងារជួសជុលបន្ទាន់ និង គ្រឿងបន្លាស់សំរាប់សំណង់ផ្សេងៗ ព្រមទាំងចំណូលផ្សេងៗទៀត ។ ការចំណាយទៅលើសកម្មភាពប្រតិបត្តិការ និង ការជួសជុលថែទាំនូវតំលៃដែលមានស្រាប់ ចំពោះបុគ្គលដែលបំរើការងារ ព្រមទាំងការថែទាំនូវសំណង់ទាំងឡាយ ឧបករណ៍ដែលមាន ផ្លាស់ប្តូរនូវឧបករណ៍របស់សំណង់ និង សំរាប់កម្មវិធីបង្កើនសមត្ថភាព ។ល។ តុល្យភាពប្រចាំឆ្នាំនៃប្រាក់ចំណូល និង ការចំណាយផ្សេងៗត្រូវតែធ្វើការសន្សំជាប់ជានិច្ច ដើម្បីនឹងផ្គត់ផ្គង់លើការចំណាយផ្សេងៗសំរាប់ជួសជុលបន្ទាន់ និង បំលាស់ប្តូរនូវឧបករណ៍របស់សំណង់នានា ។ គំរិតហិរញ្ញវត្ថុនៃការបង្កើតឡើងនូវប្រតិបត្តិការ និង ការជួសជុល បង្ហាញជាបន្តបន្ទាប់ :

**តារាងចំណូលហិរញ្ញវត្ថុសំរាប់សកម្មភាព O & M**

(ឯកតា : លានរៀល)



# ជំពូក 19 គោលបំណងនៃផែនការចូលរួម

## 19.1 លក្ខណៈទូទៅ

ទោះបីជាយ៉ាងណាក៏ដោយ គោលបំណងនៃផែនការចូលរួមគឺមិនទូទៅទេនៅប្រទេសកម្ពុជា អ្នកធ្វើផែនការគំរោងគួរទទួលយកយោបល់ និង សំណើទាំងឡាយរបស់អ្នកចូលរួមចំណែកនៅតំបន់ប្រព័ន្ធឱ្យបានច្រើនតាមដែលអាចធ្វើបាន កែប្រែផែនការ ។ ដូចនេះការប្រជុំពិសេសក្រៅផ្លូវការនានា ជាមួយអ្នកចូលរួមមិនមែនតែអ្នកទទួលផលប្រយោជន៍ទេ ក៏ប៉ុន្តែអ្នកទទួលការខូចខាតនឹងផ្តល់យោបល់ល្អៗ សំរាប់ធ្វើផែនការដែលទាក់ទាញច្រើនជាង និង ដែលពួកគាត់អាចទទួលយកបាន ។

ការស្ទាបស្ទង់ស្តាប់មតិពីអ្នកចូលរួមទាំងអស់ អាចធ្វើទៅបានដោយល្អត្រឹមត្រូវសំរាប់ប្រព័ន្ធតូចៗ ។ ប៉ុន្តែចំពោះប្រព័ន្ធខ្នាតមធ្យម និង ខ្នាតធំ វានឹងអាចគ្រប់គ្រាន់ថែមទៀតក្នុងការធ្វើតាមការស្ទាបស្ទង់ស្តាប់មតិសំរាប់ជ្រើសរើសសំណាកដើម្បីធ្វើឱ្យដំណើរការស្ទាបស្ទង់ និង លទ្ធផលកាន់តែមានប្រសិទ្ធិភាព និង មានសមធម៌ ។ "ការវាយតំលៃជនបទរហ័ស" (RRA) គឺជាបែបបទមួយនៃបែបបទផែនការចូលរួមទូលំទូលាយដែលនឹងផ្តល់ឱ្យនូវការយល់ដឹងច្បាស់លាស់អំពីការជ្រើសរើសគ្រួសារ ឬ សហគមន៍ដែលចំណាយពេលវេលាខ្លីសំរាប់ប្រៀបធៀប ។

ការប្រជុំស្តាប់មតិសាធារណៈប្រព្រឹត្តទៅក្នុងទំរង់របស់ "ការវាយតំលៃការចូលរួមជនបទ" (PRA) នឹងជួយអ្នកចូលរួមបានយល់ដឹងពីផែនការពង្រាងប្រព័ន្ធ និង ផ្តល់សេចក្តីសង្កេតរបស់ពួកគាត់សំរាប់បញ្ចប់ផែនការ ។

ការយល់ព្រមព្រៀងរបស់អ្នកចូលរួមក្នុងប្រព័ន្ធ នឹងត្រូវការជាចាំបាច់សំរាប់ការអនុវត្តន៍ដោយជោគជ័យ និង និរន្តរភាពអភិវឌ្ឍន៍ ។ ដូចនេះអ្នកចូលរួមគួរតែចូលរួមក្នុងដំណើរការផែនការ និង ប្រកាន់ខ្ជាប់ការយល់ដឹងទូទៅអំពីតួនាទីរបស់ពួកគាត់លើផលប្រយោជន៍ ឬ ផលវិបាក ។ វាក៏សំខាន់ដែរដែលអ្នកចូលរួមទាំងអស់គួរប្រកាន់យកនូវទស្សនៈឯករាជ្យ នៅក្នុងដំណើរការផែនការចូលរួម ដូច្នេះភាពលំអៀង និង សភាវៈអំណាចនៃអានុភាពមនុស្សគួរតែជៀសវាង ។

គោលបំណងនៃការចូលរួម គឺលើកទឹកចិត្តអ្នកទទួលផលប្រយោជន៍ ដើម្បីបង្កើតនូវការយល់ដឹងដូចជា "ម្ចាស់របស់គំរោង" ។ ហើយវាក៏នឹងជាដំណាក់កាលសំខាន់មួយសំរាប់ពួកគាត់ទទួលយកបច្ចេកទេស និង មូលនិធិទុនពីខាងក្រៅ ។ លក្ខខណ្ឌរបស់ទុនគួរតែបំពេញសេចក្តីត្រូវការរបស់អ្នកទទួលផលប្រយោជន៍ ។ រដ្ឋាភិបាលដែលទ្រទ្រង់ប្រព័ន្ធ ក៏គួរដឹងត្រូវយល់ថានឹងត្រូវការការខិតខំប្រឹងប្រែងជានិរន្ត ដើម្បីថែទាំប្រព័ន្ធប្រកបដោយប្រសិទ្ធិភាព និង និរន្តរភាពដោយទទួលយកការចូលរួមរបស់អ្នកទទួលផលប្រយោជន៍ ។

គោលបំណងទីមួយដែលត្រូវធ្វើ គឺត្រូវមានការយល់ដឹងច្បាស់លាស់ពីកាលៈទេសៈរបស់អ្នកទទួលផលប្រយោជន៍ ធ្វើឱ្យពួកគាត់នឹកឃើញចូលរួមក្នុងប្រព័ន្ធតាមសំរួល ។ ពីព្រោះវាមិនមែនមានតែរដ្ឋាភិបាលប៉ុណ្ណោះទេ ក៏ប៉ុន្តែសំរាប់អ្នកទទួលផលប្រយោជន៍ខ្លួនឯងដែរ ការជឿជាក់ទៅវិញទៅមក និង ការកើតមាន

ឡើងរបស់សហគមន៍ នឹងជាការគាំទ្រដ៏សំខាន់ចំពោះគោលបំណងចូលរួមសំរាប់ប្រព័ន្ធ ។

ក្នុងករណីខ្លះការប៉ះទង្គិចក្នុងចំណោមអ្នកចូលរួម អាចប៉ះពាល់មុខងាររបស់សហគមន៍ពីព្រោះតែផលប្រយោជន៍ និង ផលវិបាកដែលនឹងនាំមកដោយប្រព័ន្ធទៅក្នុងសហគមន៍ ។ ការរំពឹងទុកលំអៀងចំពោះការចូលរួមរបស់អ្នកទទួលផលប្រយោជន៍ដោយប្រព័ន្ធជាញឹកញាប់នឹងធ្វើឱ្យអ្នកទទួលផលប្រយោជន៍ស្ទាក់ស្ទើរនឹងចូលរួមក្នុងប្រព័ន្ធ ។ គួរកត់សំគាល់ថាអ្នកធ្វើផែនការប្រពន្ធ័ គួរប្រកាន់ស្មារតីអព្យាក្រិត្យជានិច្ច និង សមភាពចំពោះអ្នកចូលរួមទាំងអស់ ។

## 19.2 ការវាយតំលៃជនបទរហ័ស

"ការវាយតំលៃជនបទរហ័ស" (RPA) មានគោលបំណងពីរគឺ ❶ សម្ភាសន៍អ្នកឱ្យការណ៍គន្លឹះ និង ❷ សម្ភាសន៍បុគ្គលម្នាក់ៗ ។ សម្ភាសន៍អ្នកឱ្យការណ៍គន្លឹះ គឺធ្វើឡើងចំពោះអ្នកដឹកនាំសហគមន៍ដែលជាអ្នកមានចំណេះដឹងច្រើនផ្នែក បទពិសោធន៍ និង យោបល់ រីឯសម្ភាសន៍បុគ្គលម្នាក់ៗ គឺសំដៅទៅលើបុគ្គលម្នាក់ៗដែលជាតំណាង ឬ សាខាទូទៅនៅក្នុងតំបន់ប្រពន្ធ័ ។ "ទម្រង់សម្ភាសន៍ពីរជង" (SSI) ដែលសំរាប់អនុវត្តក្នុងសម្ភាសន៍ទាំងពីរខាងលើ ។ SSI មានតែចំណុចសំខាន់ៗដែលត្រូវសួរចំពោះអ្នកដែលមកធ្វើសម្ភាស ។ លំដាប់នៃចំនុចសំខាន់ៗអាចផ្លាស់ប្តូរជាយថាហេតុក្នុងលក្ខណៈពិសេស ។ សំនួរលំអិតលើចំនុចសំខាន់និមួយៗក៏អាចសួរដែរតាមត្រូវការ ។ ទម្រង់សម្ភាសន៍មានចំណុចលំអិតៗដែលនឹងត្រូវសួរអ្នកមកធ្វើសម្ភាស ហើយចំនុចស្ទាបស្ទង់អាចសំដៅលើភាពលំអៀងរបស់មនុស្សដែលបានរៀបចំសំនួរ ។ គោលបំណងរបស់ SSI គឺដើម្បីការពារភាពលំអៀងទាំងនោះ និង បានយល់ដឹងពីសម្ភាសន៍ ដែលបត់បែនដោយការវិនិច្ឆ័យរបស់អ្នកសួរ និង ចំលើយរបស់អ្នកមកធ្វើសម្ភាសន៍ ។

ការស្ទាបស្ទង់សម្ភាសន៍ទាំងពីរ គួរត្រូវធ្វើដោយរៀបចំជាក្រុម ដែលមានអ្នកឯកទេសអំពីវិស័យខុសៗគ្នា ។ ភាពខុសៗគ្នានៃវិជ្ជាឯកទេស នឹងបំពេញបន្ថែមគ្នាទៅវិញទៅមក ។ សំណាកនៃមុខសំនួរសំរាប់សម្ភាសន៍អ្នកឱ្យការណ៍គន្លឹះ និង សម្ភាសន៍បុគ្គលម្នាក់ៗមានបង្ហាញនៅទំព័របន្ទាប់ ។ ទិន្នន័យបន្ទាប់បន្សំគួរត្រូវរៀបចំមុនពេលសម្ភាសន៍ស្ទាបស្ទង់ ។ ទិន្នន័យបន្ទាប់បន្សំ គឺទិន្នន័យស្ថិតិ និង ផែនទី ។ លទ្ធផលរបស់បញ្ជីសំនួរស្ទាបស្ទង់ ក៏គួរត្រូវវិភាគផងដែរបើវាត្រូវធ្វើ ។ ការប្រជុំរបស់ RRA ត្រូវការពេលវេលាច្រើនជាង បី (3) ថ្ងៃ ថ្ងៃទីមួយសំរាប់ការរៀបចំទិន្នន័យបន្ទាប់បន្សំ ថ្ងៃទីពីរសំរាប់សម្ភាសន៍អ្នកឱ្យការណ៍គន្លឹះ និង ថ្ងៃចុងក្រោយសំរាប់សម្ភាសន៍បុគ្គលម្នាក់ៗ ។ សេចក្តីសង្ខេបរបស់សម្ភាសន៍នីមួយៗ គួរត្រូវធ្វើនៅថ្ងៃតែមួយដើម្បីកុំឱ្យខូចលទ្ធផលសម្ភាសន៍ ដែលអាចភ្លេចទៅតាមពេលវេលាកន្លង ។ របាយការណ៍អង្គប្រជុំគួរត្រូវរៀបចំបើមានក្រុមច្រើនដែលរៀបចំ ដើម្បីប្រតិបត្តិការស្ទាបស្ទង់ច្រើននៅពេលតែមួយ ។ ការចែករំលែកពត៌មាន និង ការយល់ដឹងពីបញ្ហាទាំងឡាយដែលរកឃើញពេលស្ទាបស្ទង់មតិជាមួយអ្នកចូលរួមទាំងអស់គឺវាសំខាន់ ។ របាយ-ការណ៍ពីលទ្ធផលរបស់ RRA នឹងជួយឱ្យបានងាយយល់ពីអ្នកធ្វើផែនការដទៃទៀត ដែលមិនអាចចូលរួមក្នុងការស្ទាបស្ទង់ RRA ។ សំណាករបាយការណ៍របស់ RRA មានបង្ហាញក្នុង **តារាង 19-1** ។

## (1) សម្ភាសន៍អ្នកឱ្យការណ៍គន្លឹះ

| **ផែនទី** | |
|---|---|
| គំនូសព្រាងសរីរៈ : | ព្រំប្រទល់ភូមិ ទីតាំងជិតខាង ផ្លូវថ្នល់ ធនធានទឹក ដីទូទៅ ការតាំងទីលំនៅក្នុងភូមិ និង ផ្សេងៗ |
| ឋានលេខាសាស្ត្រ : | ប្រភេទដីសំខាន់ និង គំរូដីប្រើប្រាស់ |
| ដីដាំដុះ : | ប្រភេទដីដាំដុះ ការចែកចាយ និង បញ្ហា ។ ការផ្លាស់ប្តូរជីជាតិដីដាំដុះ និង ការគ្រប់គ្រងដីដាំដុះ ។ |
| ធនធានទឹក : | ប្រភពទឹកសំរាប់មនុស្សនិងប្រើប្រាស់ក្នុងកសិកម្ម ភាពផ្លាស់ប្តូរតាមរដូវ និង រយៈពេលវែងក្នុងការផ្គត់ផ្គង់ទឹក ការអនុវត្តន៍ ការគ្រប់គ្រងទឹក បញ្ហា និង កាលៈទេសៈ ។ |
| ការប្រើប្រាស់ដី : | ផ្ទៃក្រឡា ប្រភេទ ភាពអាចរកបាន ការប្រើប្រាស់និងការគ្រប់គ្រង |
| ហេដ្ឋារចនាសម្ព័ន្ធ : | ហេដ្ឋារចនាសម្ព័ន្ធផែនទី (ទីតាំងគ្រួសារ ផ្លូវថ្នល់ សំណង់សាធារណៈ) សាលារៀន វត្ត អគ្គិសនី និង ការដឹកជញ្ជូន ។ |

| **ដំណាំ** | |
|---|---|
| ដំណាំ : | ប្រភេទ និង ពូជ (បញ្ជីសារពើភណ្ឌដំណាំ) ទិសដៅនៃការដាំដុះដំណាំមួយៗ ប្រក្រតិទិនដំណាំ |
| ការអនុវត្តន៍ : | មុនពេលដាំដុះ ការដាំដុះ ការច្រូតកាត់ និង ក្រោយពេលច្រូតកាត់ (ការប្រើប្រាស់ ជី និង ថ្នាំសំលាប់សត្វល្អិត) |
| គំរូរបស់ជី និង ការប្រើប្រាស់ពលកម្ម | |
| ផលិតផល និង ការចែកចាយផលិតផល | |
| បញ្ហា : | កត្តាកំណត់សំរាប់ផលិតកម្មដំណាំសំខាន់ និង កាលៈទេសៈ |

| **បសុសត្វ និង នេសាទ** | |
|---|---|
| ប្រភេទ និង ពូជ/ជំពូក | |
| ការប្រើប្រាស់បសុសត្វ : | ការប្រើប្រាស់ សេដ្ឋកិច្ច និង ទំនៀមទំលាប់ |
| ការអនុវត្តន៍វប្បធម៌ : | ការចិញ្ចឹម ទីជំរក និង ការត្រួតពិនិត្យជម្ងឺ |
| ប្រក្រតិទិនរបស់សត្វ | |
| ការទទួលបច្ចេកវិទ្យា | |
| បញ្ហា : | កត្តាកំណត់សំរាប់ផលិតកម្មបសុសត្វ និង កាលៈទេសៈ |

| **ទិន្នន័យសេដ្ឋកិច្ច** | |
|---|---|
| មុខរបរ, ចំណូលនិងចំណាយ: | ប្រភេទមុខរបរ (ចំនួន HHs ដែលចូលរួមក្នុងសកម្មភាពនីមួយៗ) |
| គំរូការប្រើប្រាស់ពលកម្ម : | ប្រក្រតិទិនពលកម្ម |
| ទីផ្សារ និង ឥណទាន : | ទីផ្សារសំរាប់ផលិតផល ធុន ទំនិញ និង ពលកម្ម ។ ការផ្លាស់ប្តូរទំនិញ ឥណទានផ្លូវការ និង ក្រៅផ្លូវការ ។ ផ្សាក្រោមរំហូរ |
| រយៈពេលកាន់កាប់ដី : | ការចែកចាយដីកាន់កាប់ ។ ភាពជាម្ចាស់ដី ។ ប្រពន្ធ័ដីកេរ្តិ៍មរតក ។ |
| ជាន់ថ្នាក់សង្គម : | លក្ខណៈវិនិច្ឆ័យដែលប្រើសំរាប់កំណត់ជាន់ថ្នាក់សង្គម ។ លក្ខណៈ ~ និង ចំនួនគ្រួសារនៅជាន់ថ្នាក់នីមួយៗ ។ លំដាប់ថ្នាក់ទ្រព្យសម្បត្តិ |

| **ក្រុម និង ញាតិសន្តាន** | |
|---|---|
| ក្រុម : | ចំនួនក្រុមសំខាន់ៗ (ក្រុមផ្លូវការ និង ក្រៅផ្លូវការ) ។ ក្រុមបង្កើត និង ទិសដៅ ។ ក្រុមសកម្មភាព ។ អ្នកដឹកនាំ និង គណៈកម្មការ ។ទំនាក់ទំនងជាមួយក្រុមដទៃទៀត( ការផ្លាស់ប្តូរពត៌មានដើមទុន ពលកម្ម ការផ្គត់ផ្គង់ ដំបូន្មាន និង ផ្សេងៗ) ។ |
| ញាតិសន្តាន | ញាតិសន្តានបឋមដែលមានទីតាំងនៅក្នុងភូមិ (ញាតិសន្តានមួយណា) ។ តើពួកគាត់បានមកពីទីណា?<br>ទំនាក់ទំនងរវាងញាតិសន្តាន (ផ្សាក្រោមញាតិសន្តាន) ។ ឈ្មោះរបស់ញាតិសន្តាន ។ មង្គលការរវាងញាតិសន្តាន ។<br>ញាតិសន្តានដែលមានទីតាំងក្នុងភូមិ ផ្លាស់ប្តូរទីលំនៅ ។ ទំនាក់ទំនងរបស់ក្រុមគ្រួសារនៅក្នុងភូមិ ។ តើញាតិសន្តានមួយណាដែលបានរួមបរិច្ចាគយ៉ាងខ្លាំងលើការអភិវឌ្ឍន៍ភូមិ? |

**ទិន្នន័យវប្បធម៌សង្គម**

ប្រវត្តិសាស្ត្ររបស់ភូមិ : ប្រវត្តិសាស្ត្រនៃការតាំងទីលំនៅរបស់ភូមិ ។ ព្រឹត្តិការណ៍សំខាន់ៗនៅក្នុងភូមិ / ក្រៅភូមិ ( ពេលវេលា)

ចំនួនប្រជាជន : ចំនួនគ្រួសារ ចំនួនប្រជាជន ភេទ អត្រា ក្រុមជនជាតិ អត្រាកំណើត ការផ្លាស់ ប្តូរទីលំនៅ ( តាមរដូវ និង អចិន្ត្រៃយ៍) ។

ប្រក្រតិទិនបុណ្យ : ជំនឿ និង បំរាម ( ក្នុងការទាក់ទង និង ការប្រើប្រាស់ធនធាន) ។

ការអភិវឌ្ឍន៍គំរោងនៅក្នុងភូមិ :

ប្រភេទទីភ្នាក់ងារ និង សកម្មភាព

ហេដ្ឋារចនាសម្ពន្ធ័សង្គម : ការសិក្សា (ការសិក្សាផ្លូវការ និង ក្រៅផ្លូវការ ការយល់ដឹងរបស់ឪពុកម្តាយអំពីការសិក្សារបស់កូនគាត់) ។សុខភាព សេវាសុខភាព ថ្នាំពេទ្យ និង ថ្នាំបុរាណ ជម្ងឺទូទៅ ការខ្វះចំណីអាហារ ។ អត្រាស្លាប់របស់កុមារ អនាម័យ) ។ សាសនា ( តួនាទីរបស់ព្រះសង្ឃនៅក្នុងភូមិ)

## (2) សម្ភាសន៍អ្នកឱ្យការណ៍ម្នាក់ៗ

**រចនាសម្ព័ន្ធគ្រួសារ**

ចំនួនសមាជិករបស់គ្រួសារ អាយុ ភេទ និង ការងាររបស់សមាជិកទាំងអស់ ចំនួនកម្មករ ( ពេញម៉ោង និង ពាក់កណ្តាលម៉ោងផ្សេងៗពីគ្នា) ភាពខុសគ្នាតាមរដូវកាល ( ការសិក្សានៅកន្លែងដទៃការងារដែលផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត) ស្ថានភាពសុខភាព ។

**ដី**

ការចែកចាយ ( ទីកន្លែង) របស់ដី ( តួរផ្ទះរបស់គាត់/នាង) ផ្ទៃក្រឡា រយៈពេលកាន់កាប់ដី( ភាពជាម្ចាស់) ការប្រើប្រាស់ ( ប្រភេទដំណាំទិន្នផល ប្រភពទឹកសំរាប់ដំណាំ និង លក្ខណៈរបស់វា)

**ការអនុវត្តន៍កសិកម្ម**

ពូជដំណាំ បំណងរបស់ដំណាំនីមួយៗ ( ការប្រើប្រាស់ខ្លួនឯង ទិញ) ការអនុវត្តន៍កសិកម្ម ( ការទុកពូជ ច្រូតកាត់ និង ក្រោយពេលច្រូតកាត់ ការវិលរបស់ដំណាំ )ទុនការងារ ( ពលកម្មគ្រួសារ ការជួលពលកម្ម ការងារប្រវាស់) ការប្រើប្រាស់ថ្នាំគីមី ជី ជីលាមកសត្វ ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ទិន្នផល បណ្តាញទីផ្សារ

**បសុសត្វ និង នេសាទ**

ការចិញ្ចឹមគំរូ ពូជរបស់បសុសត្វ និង ត្រី គោលបំណងនៃការចិញ្ចឹម លក្ខណៈ និង ទីកន្លែងរបស់កសិដ្ឋាន ចិញ្ចឹម ការត្រួតពិនិត្យជម្ងឺ

**ប្រាក់ចំណូលក្រៅពីកសិកម្ម**

ប្រភេទការងារក្រៅពីកសិកម្ម ( សិប្បកម្ម ដើរលក់អីវ៉ាន់កំប៉ិកកំប៉ុក ពលកម្មកសិដ្ឋាន ការងារដែលផ្លាស់ពីកន្លែងមួយទៅកន្លែងមួយទៀត) គោលបំណងប្រាក់ចំណូល

**ប្រាក់ចំណូល និង ប្រាក់ចំណាយ**

ប្រភពប្រាក់ចំណូល ( ប្រភព និង ចំនួន) រំហូរប្រាក់ ទ្រព្យសម្បត្តិ ( ប្រាក់សន្សំអចលនទ្រព្យ ទូរស័ព្ទ ម៉ូតូ ត្រាក់ទ័រ ទូរទស្សន៍ ទូរទឹកកក)

**ប្រាក់សន្សំ និង ប្រាក់បំណុល**

បំណុលផ្លូវការ និង ក្រៅផ្លូវការ ( អ្នកឱ្យខ្ចីប្រាក់ឯកជន) ការប្រាក់សំរាប់ប្រាក់បំណុល សំណើសំរាប់ប្រាក់បំណុល

**អ្នកធ្វើសេចក្តីសំរេច និង បញ្ហា**

អ្នកធ្វើសេចក្តីសំរេចសំរាប់ការចំណាយ ( ការចំណាយធម្មតា និង ការចំណាយថ្ងៃៗ) បញ្ហាផ្សេងៗសំរាប់ការរស់នៅ ( ភាពតានតឹង និង បញ្ហាក្នុងស្រុក)

## 19.3 ការរាយតំលៃការចូលរួមជនបទ និង ការប្រជុំស្តាប់មតិសាធារណៈ

ពង្រាងផែនការប្រព័ន្ធដែលបានរៀបចំយ៉ាងជាក់លាក់ដោយអ្នកធ្វើផែនការ ដោយប្រើប្រាស់ពត៌មានផ្សេងៗនិងការវាស់ស្ទង់ការដ្ឋាន គួរត្រូវបើកយ៉ាងត្រឹមត្រូវចំពោះសាធារណៈជន ឬ អ្នកចូលរួមមុនពេលការអនុវត្តន៍ ដូច្នោះអ្នកធ្វើផែនការអាចឆ្លើយទៅនឹងសំនួររបស់ពួកគេ ទទួលការសង្កេត និង យោបល់ហើយកែប្រែពង្រាងផែនការទៅផែនការបញ្ចប់ដោយអនុវត្តតាមការសង្កេតទាំងនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនទាន់គ្រប់គ្រាន់សំរាប់សំរេចគោលបំណងរបស់គំរោង ដែលអ្នកធ្វើផែនការបានចែកចាយក្រដាសពន្យល់ណែនាំអំពីគំរោងទៅអ្នកចូលរួម ឬ ធ្វើការប្រជុំមួយ ដើម្បីពន្យល់តែផែនការប៉ុណ្ណោះ ។

អ្នកទទួលផលប្រយោជន៍ដែលបានសន្មតក្នុងតំបន់ជនបទមិនដែលធ្លាប់ក្នុងការប្រជុំទាំងនេះទេ ហើយវាពិបាកខ្លាំងណាស់ក្នុងការធ្វើឱ្យអ្នកទទួលផលប្រយោជន៍ទាំងនេះយកចិត្តទុកដាក់ និង យល់ឬបង្ហាញពីបញ្ហានិងតំរូវការរបស់ពួកគាត់ ។ ដូច្នោះ "ការប្រជុំស្តាប់មតិសាធារណៈ" ត្រូវបានយល់ព្រមសំរាប់ធ្វើឱ្យដំណើរការផែនការចូលរួមរបស់អ្នកទទួលផលប្រយោជន៍បានងាយស្រួល និង ដែលអាចមានជោគជ័យ ។

ការប្រជុំស្តាប់មតិសាធារណៈ ត្រូវបានចាត់ចែងដោយអ្នកសំរបសំរួលដែលបានបណ្តុះបណ្តាលយ៉ាងល្អដែលជាអ្នកចេះផ្លាស់ប្តូរសំរើក និង សម្រួលមាតិការសំរាប់សំនួរទៅតាមការយល់ដឹងរបស់អ្នកចូលរួម និង បង្កើតបរិយាកាសមួយដែលធ្វើឱ្យអ្នកចូលរួមមានអារម្មណ៍ល្អសំរាប់ចូលរួមការពិភាក្សា ។ ក្នុងករណីដែលអត្រាចេះអាន សរសេរអក្សររបស់អ្នកចូលរួមទាប សំភារៈសំរាប់ពន្យល់បង្ហាញពីគំរោងប្រព័ន្ធ ឬ ផ្សេងៗទៀតគួរត្រូវរៀបចំ ។ ជាការប្រសើរអ្នកសំរបសំរួលសំរាប់ការប្រជុំស្តាប់មតិសាធារណៈ គួរតែជ្រើសរើសពីអ្នកដែលបានបណ្តុះបណ្តាលអំពី PRA ។ PRA គឺជាបែបបទមួយរបស់បែបបទសេរី ដែលត្រូវបានប្រើជាទូទៅសំរាប់ដំណាក់កាលសិក្សាអំពីគោលបំណងប្រព័ន្ធជាមួយប្រជាជនក្នុងស្រុក និង អ្នកក្រៅសិក្សាទៅវិញទៅមក ។ ម្យ៉ាងវិញទៀតផលប្រយោជន៍ភាគច្រើនរបស់ PRA អាចនឹងអនុវត្តសំរាប់ការប្រជុំស្តាប់មតិសាធារណៈនៅដំណាក់កាលផែនការ ។

ក្រៅពីអ្នកសំរបសំរួល អ្នកធ្វើផែនការ ក៏គួរចូលរួមដែរនៅក្នុងការប្រជុំពីព្រោះសំនួរលំអិតអំពីប្រព័ន្ធអាចនឹងត្រូវសួរ ។ អ្នកធ្វើផែនការដែលជាអ្នកប្រៀបធៀបអ្នកដែលបានចូលរួមក្នុងការប្រជុំនោះ ត្រូវតែយល់ពីផែនការទាំងមូលរបស់ប្រព័ន្ធ ។ ការប្រជុំជាមួយប្រធានរដ្ឋបាលសាធារណៈ ដូចជា ខេត្រ ស្រុក និង ឃុំ គួរតែធ្វើឡើងដោយឡែកពីគ្នា ដោយគ្មានអ្នកចូលរួមឡើយ ដូច្នេះពួកគាត់មិនគួរស្ទាក់ស្ទើរក្នុងការបញ្ចេញយោបល់ឡើយ ។ ក្នុងករណីខ្លះប្រធានភូមិនឹងមិនត្រូវបានអញ្ជើញចូលរួមប្រជុំ សំរាប់គោលបំណងដូចគ្នា ។ ស្ថានភាពនេះ និង បរិយាកាសអាចនឹងដឹងបានតាមរយៈការស្ទាបស្ទង់ដំបូងដូចជា RRA ។

ទោះបីជាអ្នកចូលរួមទាំងអស់គួរមានឱកាសចូលរួមក្នុងការប្រជុំស្តាប់មតិសាធារណៈក៏ដោយ និង បង្ហាញពីមតិផ្ទាល់របស់ពួកគាត់ ឬ ស្នើអំពីពង្រាងផែនការ វានឹងមិនអាចធ្វើការប្រជុំដោយអញ្ជើញអ្នកចូលរួមទាំងអស់បានទេ ពីព្រោះពេលខ្លះអាចលើសពីមួយពាន់នាក់សំរាប់ប្រព័ន្ធខ្នាតធំៗ ។ នៅពេលដែលគោលបំណង

របស់ការប្រជុំបានយល់ច្បាស់ពីបញ្ហារបស់ពង្រាងផែនការសំរាប់អ្នកចូលរួម និង ដើម្បីស្តាប់សំណូមពររបស់ពួកគាត់ ការប្រជុំគួរត្រូវធ្វើឡើងជាមួយតំណាងរបស់ក្រុមនីមួយៗ ដែលបានចែកប្រភេទដោយអ្នកធ្វើផែនការ ។ អ្នកចូលរួមនឹងត្រូវចែកទៅក្នុងក្រុមទាំងនេះដូចខាងក្រោម ។

(1) ក្រុមដែលនឹងបាត់ដី និង ទ្រព្យសម្បត្តិផ្សេងៗដោយការស្តារឡើងវិញ ឬ ការស្ថាបនាឡើងវិញនូវអាងទឹក និង សំណង់ស្រោចស្រព

(2) ក្រុមអ្នកទទួលផលប្រយោជន៍ ដែលមួយចំនួននឹង ឬ មានទឹកស្រោចស្រពគ្រប់គ្រាន់

(3) ក្រុមនារី រួមទាំងនារីជាមេគ្រួសារ

(4) ក្រុមកសិករដែលធ្វើស្រែធំៗលើសពី 2 ហ.ត

(5) ក្រុមកសិករដែលធ្វើស្រែតូចៗតិចជាង 0.2 ហ.ត

(6) ប្រធានភូមិ និង ប្រធានគណៈកម្មការអភិវឌ្ឍន៍ភូមិ (VDC)

(7) រដ្ឋបាលមូលដ្ឋានដូចជា ឃុំ ស្រុក និង ខេត្ត និង

(8) អង្គការក្រៅរដ្ឋាភិបាល (NGO) និង អង្គការអន្តរជាតិ (IO) ដែលពាក់ព័ន្ធ

ទោះបីជាយ៉ាងណាក៏ដោយ វាចាំបាច់ធ្វើសហប្រតិបត្តិការជាមួយប្រធានឃុំ និង ប្រធានភូមិ ដើម្បីទទួលការយល់ព្រមអំពីប្រព័ន្ធ ពីអ្នកចូលរួមទាំងអស់ ។ ដូច្នោះការប្រជុំមួយចំនួនដោយមានការចូលរួមពីបណ្តាអ្នកចូលរួមផ្សេងៗនឹងត្រូវការ ។

## 19.4 គោលបំណងនៃការចូលរួមផ្សេងៗ

"ការវាយតំលៃការចូលរួម" របស់ប្រព័ន្ធដោយអ្នកធ្វើផែនការ អ្នកទទួលផលប្រយោជន៍ និង អ្នកដទៃទៀតដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធ គួរធ្វើឡើងដើម្បីវាយតំលៃសកម្មភាពរបស់ពួកគាត់ ដោយប្រៀបធៀបជាមួយនឹងផែនការសកម្មភាព ។ ការវាយតំលៃដោយអ្នកខាងក្រៅក៏អាចនឹងមានប្រសិទ្ធិភាពដែរ ។ លទ្ធផលនៃការវាយតំលៃគួរតែជាពត៌មានដែលត្រឡប់មកប្រព័ន្ធវិញ ដើម្បីកែលំអរពង្រាងផែនការ។ ទោះបីជាយ៉ាងណាក៏ដោយ បើលទ្ធផលខ្លះដែលបានវាយតំលៃដោយអ្នកខាងក្រៅ មានចំណុចអវិជ្ជមានដែលផ្ទុយនឹងប្រព័ន្ធខ្លួនឯង លទ្ធផលនេះនឹងមិនអាចទទួលយកបានទេចំពោះអ្នកដែលពាក់ព័ន្ធទៅនឹងប្រព័ន្ធ ។

ដើម្បីកែលំអ និង និរន្តរភាពនៃការអភិវឌ្ឍន៍របស់ប្រព័ន្ធ វាសំខាន់ណាស់ដែលប្រជាជនពាក់ព័ន្ធទៅនឹងប្រព័ន្ធ គួរតែចូលរួមក្នុងការវាយតំលៃ វិភាគបញ្ហា និង រកវិធានការណ៍ទប់ទល់ ។ អ្នកពាក់ព័ន្ធនឹងប្រព័ន្ធនឹងបានទទួលជំនាញសំរាប់ការវាយតំលៃនេះ ។ ពួកគាត់ថែមទាំងបានបង្កើនការយល់ដឹងដែលពាក់ពន្ធ័នឹងប្រព័ន្ធតាមរយៈការចូលរួមក្នុងដំណើរការវាយតំលៃ ។

គោលបំណងនៃការវាយតំលៃការចូលរួមគឺ (1) ពង្រឹងសមត្ថភាពគ្រប់គ្រង (2) ពង្រឹងការយល់ដឹងពីភាពជាម្ចាស់ (3) ទទួលពត៌មានដែលមានប្រសិទ្ធភាព និង (4) ការកែលំអភាពអាចទទួលខុសត្រូវបាន ។ អ្នកចូលរួម រួមទាំងអ្នកទទួលផលប្រយោជន៍ គួរចូលរួមក្នុងការវាយតំលៃ ការរៀបចំផែនការវាយតំលៃ ការផ្គត់ផ្គង់ប្រមូល និង វិភាគពត៌មាន និងកែប្រែផែនការដើមតាមដែលអាចធ្វើបាន ។ ការវាយតំលៃនឹងមិន

ធ្វើឡើងតែនៅពេលបញ្ចប់ប្រព័ន្ធប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏នៅពេលចាប់ផ្ដើមដែរ (ការវាយតំលៃមុន និង ត្រួតពិនិត្យប្រព័ន្ធកំពុងតែមាន គឺចាត់ទុកជាសកម្មភាពវាយតំលៃមួយ) ។

"ប្រព័ន្ធការគ្រោងម៉ាទ្រិក (Project Design Matrix) (PDM)" គឺប្រើសំរាប់ "ប្រព័ន្ធគ្រប់គ្រងវិលចុះវិលឡើង (Project Cycle Management) (PCM)" ។ PCM គឺជាបែបបទមួយសំរាប់ផែនការចូលរួម ត្រួតពិនិត្យ និង ការវាយតំលៃ ។ PDM ប្រើសំរាប់គ្រប់ដំណាក់កាលទាំងអស់របស់ PCM ។ "គោលបំណងប្រព័ន្ធ" "សកម្មភាព" "ទុន" និង "ការប្រើប្រាស់សំខាន់" បានរៀបចំជាមួយសន្លឹក (PDM) ហើយទាំងអស់នេះបានទំនាក់ទំនងទៅវិញទៅមក ។ សំណាករបស់ PDM មានភ្ជាប់ក្នុង តារាង 19.2 ។ PCM គឺជាទម្រង់បែបបទ ដ៏សមហេតុសមផលមួយ ។

**(1) គោលបំណងផែនការចូលរួម**

អ្នកចូលរួមរបស់ប្រព័ន្ធមួយ (ដែលពាក់ព័ន្ធនឹងរដ្ឋបាល អ្នកទទួលផលប្រយោជន៍ ទីភ្នាក់ងារការងារ និង អ្នកធ្វើផែនការដូចជាទីប្រឹក្សា) នឹង ចូលរួមក្នុងសិក្ខាសាលា PCM និង រៀបចំផែនការជាក់លាក់មួយ ។ ក្នុងសិក្ខាសាលា "ការវិភាគការចូលរួម" "ការវិភាគបញ្ហា" "ការវិភាគទិសដៅ" និង "ការជ្រើសរើសគំរោង" PDM និង ផែនការការធ្វើឱ្យសកម្មឡើងនឹងត្រូវបានធ្វើ ។ PDM នឹងត្រូវធ្វើនៅដំណាក់កាលចុងក្រោយរបស់សិក្ខាសាលាជាមួយនឹងអ្នកចូលរួមទាំងអស់ និង ផែនការការធ្វើឱ្យសកម្មភាពលំអិត នឹងត្រូវធ្វើឡើងដោយអ្នកធ្វើផែនការ ។

**(2) ការត្រួតពិនិត្យ និង ការវាយតំលៃ**

គោលបំណងនៃការត្រួតពិនិត្យប្រព័ន្ធដោយប្រើបែបបទ PCM មាន :

i) ត្រួតពិនិត្យថាតើប្រព័ន្ធបានធ្វើបានដោយអនុលោមតាមប្លង់ដើមទេ និង

ii) កែប្រែផែនការ និង PDM យោងទៅតាមការប្រព្រឹត្តទៅ ។ ហើយគោលបំណងរបស់ការវាយតំលៃ គឺដើម្បីត្រួតពិនិត្យលើដំណើរប្រព្រឹត្តទៅ និង បញ្ចប់របស់ប្រព័ន្ធ លើប្រាំចំណុចនៃការវាយតំលៃ * ដូច្នេះការជូនយោបល់ចំពោះប្រព័ន្ធនាពេលអនាគត និង មេរៀនទាំងឡាយសំរាប់ប្រព័ន្ធផ្សេងៗទៀតដែលនឹងអនុវត្ត ។